កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០១១

សោកនាដកម្មកោះពេជ្រ ៖ មួយឆ្នាំកន្លងផុត សំណួរនៅតែបន្ត

សេចក្តីផ្តើម

កំណត់ត្រាខ្លីនេះសង្ខេបខ្លឹមសារ នៃរបាយការណ៍ «សោកនាដកម្មកោះពេជ្រ ៖ មួយឆ្នាំកន្លងផុត សំណួរនៅតែបន្ត» (ហៅកាត់ «របាយការណ៍») ដែលនឹងដាក់ជូនក្រៅវែកញែក ចំពោះបណ្តាព្រឹត្តិការណ៍នៅរាត្រីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ខណៈដែលមនុស្សជាង ៣៥០ នាក់ បានបាត់បង់ជីវិតក្នុងឧបទ្ទវហេតុកកស្ទះជាប់គ្នា កើតឡើងលើស្ពានពេជ្រ អំឡុងព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០១០កន្លងទៅ ។ កំណត់ត្រាខ្លីមួយនេះត្រូវបានតាក់តែងឡើង ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(«ម.ស.ម.ក») ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការលើកកម្ពស់និងការពារ លទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ។

ព្រះរាជពិធីបុណ្យអុំទូក ដែលមានអាយុកាលរាប់សតវត្សរ៍មកហើយនោះ គឺជាពិធីប្រចាំឆ្នាំដ៏ឱឡារិកបំផុតនៅកម្ពុជា ដោយមានអ្នកមកចូលរួមទស្សនា ទាំងជាតិនិងអន្តរជាតិ ធ្វើដំណើរយ៉ាងកុះករ ទៅកាន់រាជធានីភ្នំពេញ ដើម្បីមើលសកម្មភាពប្រារព្ធពិធីបុណ្យនិងការប្រណាំងទូក ។ ថ្វីបើយ៉ាងនេះ សោកនាដកម្មមួយបានកើតឡើង នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ខណៈដែលក្រុមមហាជនដ៏ច្រើនកុះករ បានប្រជ្រៀតគ្នាចូលទៅស្ពានពេជ្រ ដែលមានលក្ខណៈតូចចង្អៀត ប្រើសម្រាប់តែថ្មើរជើង និងភ្ជាប់រាជធានីភ្នំពេញជាមួយនឹងកោះពេជ្រ ។ មនុស្សម្នាជាច្រើននាក់បានក្លាយជាពុំអាចរើខ្លួនរួច និងត្រូវបានជាប់កុនក្នុងឧបទ្ទវហេតុកកស្ទះជាប់គ្នាតែម្តង ។ ជាលទ្ធផល មនុស្សចំនួនជាង ៣៥០ នាក់ បានបាត់បង់ជីវិត និងចំនួនប្រហាក់ប្រហែលនេះទៀតបានរងរបួស ។ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា លោក ហ៊ុន សែន បានចាត់ទុកគ្រោះថ្នាក់នេះ ថាជាសោកនាដកម្មដ៏អាក្រក់បំផុតពុំធ្លាប់មាន ក្រោយពីរបបខ្មែរក្រហមបានដួលរលំ ។[1]

សោកនាដកម្មបានកើតឡើងអស់ពេលជិតមួយឆ្នាំកន្លងទៅហើយ តែសំណួរនៅតែបន្ត ៖ តើអ្វីខ្លះដែលបង្កឲ្យកើតចលាចល និងឧបទ្ទវហេតុកកស្ទះជាប់គ្នានៅលើស្ពាន? តើវិធានការខាងសន្តិសុខនិងសុខាភិបាលអ្វីខ្លះ ដែលត្រូវបានអនុវត្តក្នុងពេលបុណ្យអុំទូក និងពិសេសនោះ គឺក្នុងតំបន់ជុំវិញស្ពានពេជ្រ? តើមនុស្សត្រូវបានខ្សែភ្លើងឆក់ឬទេ? តើចំណាត់ការសង្គ្រោះបន្ទាន់ មានលក្ខណៈគ្រប់គ្រាន់ឬយ៉ាងណា? តើមានវិធានការថ្មីដែរឬទេ នឹងត្រូវបានដាក់ឲ្យអនុវត្តក្នុងពិធីបុណ្យអុំទូកនាពេលអនាគត ដើម្បីធានាថាព្រឹត្តិការណ៍សោកនាដកម្មបែបនេះ មិនកើតច្រំដែលជាថ្មីទៀត?

---

[1] សារព័ត៌មានឌឺខេមបូឌាដេលី ចំណងជើង "នៅមិនទាន់មានភាពច្បាស់លាស់ថា នរណាជាអ្នកទទួលខុសត្រូវក្នុងឧបទ្ទវហេតុផ្តើលរត់ជាន់គ្នា" ចុះផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ម.ស.ម.កព្យាយាមពិភាក្សាបណ្តាសំណួរទាំងអស់នេះ និងសំណួរផ្សេងទៀត ដែលសុទ្ធសឹងពុំទាន់មានចម្លើយ ហើយនិងព្យាយាមវិភាគបណ្តាព្រឹត្តិការណ៍សោកនាដកម្មនានា ដែលបានកើតឡើងលើស្ពាន ។ កំណត់ត្រាខ្លីនេះសង្ខេប អំពីបណ្តាចំណុចពិភាក្សាទាំងអស់នេះ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍ ។ គួរបញ្ជាក់ផងដែរថា របាយការណ៍នេះពុំបានព្យាយាមផ្តល់ចម្លើយជាក់លាក់ ចំពោះបណ្តាសំណួរដែលនៅសល់ទាំងអម្បាលម៉ាន ជុំវិញអ្វីៗដែលបានកើតឡើងនៅរាត្រីថ្ងៃនោះឡើយ ។ របាយការណ៍នោះគ្រាន់តែលើកឡើងជាសំណួរ និងពិភាក្សាលើបញ្ហា ដែលកើតចេញពីឧបទ្ទវហេតុកកស្ទះជាប់គ្នា និងលើព្រឹត្តិការណ៍អំឡុងប៉ុន្មានថ្ងៃក្រោយពីកើតឧបទ្ទវហេតុនោះភ្លាម ព្រមទាំងពិភាក្សាអំពីរបៀបរបប ដែលរាជរដ្ឋាភិបាលធ្វើចំណាត់ការឆ្លើយតបនឹងសោកនាដកម្មនោះប៉ុណ្ណោះ ។

សំណួរពុំទាន់មានចម្លើយ

មានសំណួរជាច្រើននៅពុំទាន់មានចម្លើយ ដូចជា ថាតើគ្រោះថ្នាក់នេះបានកើតឡើងតាមរបៀបណា និងថាតើមានកត្តាអ្វីខ្លះចូលរួមចំណែក ធ្វើឲ្យកើតគ្រោះថ្នាក់នេះឡើង ។ ជាឧទាហរណ៍ ប្រព័ន្ធផ្លូវឯកទិសគួរត្រូវបានគេអនុវត្តនៅលើស្ពាន ប៉ុន្តែទំនងពុំមានការអនុវត្តបែបនេះ ឲ្យបានខ្ជាប់ខ្ជួននោះឡើយ ។ សាក្សីជាច្រើនដែលម.ស.ម.កបានសាកសួរ បានបញ្ជាក់ថា មនុស្សម្នាបានធ្វើដំណើរក្នុងទិសដៅទាំងពីរទិស គឺទាំងទៅទាំងមក ហើយថា អាជ្ញាធរពុំបានពង្រឹងការអនុវត្តប្រព័ន្ធផ្លូវឯកទិស ឲ្យបានត្រឹមត្រូវនោះទេ ។ ប៉ូលីសមួយរូបមកពីភ្នំពេញ ដែលម.ស.ម.កសម្ភាស ក៏បានមានប្រសាសន៍ដែរថា នៅពេលកើតមានឧបទ្ទវហេតុនោះ មានប៉ូលីសតែពីរបីនាក់ប៉ុណ្ណោះ កំពុងឈរប្រចាំការនៅទីនោះ ហើយប៉ូលីសទាំងនោះហើយ ដែលអនុញ្ញាតឲ្យមនុស្សម្នា ធ្វើដំណើរតាមទិសដៅទាំងទៅទាំងមក ។

ក៏មានសេចក្តីរាយការណ៍ផងដែរ ដែលថាមានរបាំងផ្លូវដាក់នៅចុងសងខាងនៃស្ពាន ។ វាហាក់ដូចជាច្បាស់ដែរថា ការប្រើប្រាស់របាំងនេះបានចូលរួមចំណែក ធ្វើឲ្យទំហំនៃគ្រោះថ្នាក់កាន់តែកើនធំ ហើយតាមពិតទៅវាបានចូលរួមជាដើមចមនៃគ្រោះថ្នាក់ ។ ជាឧទាហរណ៍ របាំងផ្លូវនេះហាក់បានបង្កជាឧបសគ្គ ដល់ក្រុមមហាជនកុំឲ្យអាចផ្លាស់ទី ចេញពីឧបទ្ទវហេតុកកស្ទះជាប់គ្នា ដែលអាចចូលរួមធ្វើឲ្យមនុស្សប្រមូលផ្តុំគ្នានៅលើស្ពាន និងបានរារាំងមនុស្សកុំឲ្យអាចសម្រួល ដល់សភាពកកស្ទះស្ថិតនៅចំកណ្តាលស្ពានបាន ។ របាំងនេះអាចជាកត្តាសំខាន់មួយ ថ្វីបើមិនមែនជាកត្តាចម្បងក៏ដោយចុះ ដែលធ្វើឲ្យមនុស្សដួលទៅក្រោម និងគរលើគ្នាជាបន្តបន្ទាប់ ។

ទាំងកង្វះខាតកិច្ចពង្រឹងការអនុវត្តប្រព័ន្ធផ្លូវឯកទិស និងការដាក់របាំងផ្លូវនៅចុងសងខាងស្ពាន សុទ្ធសឹងបង្ហាញ ពីបរាជ័យនៃវិធានការសន្តិសុខរបស់អាជ្ញាធរ និងពីការខ្វះខាតការវាយតម្លៃ ថាសោកនាដកម្មបែបនេះអាចកើតឡើង ។

ទោះបីបើសេចក្តីលម្អិតនៃរាត្រីថ្ងៃ២២វិច្ឆិកា ពុំមានភាពច្បាស់លាស់ គេហាក់ដឹងច្បាស់ ថាមនុស្សម្នានៅលើស្ពានបានជ្រួលច្របល់ ដោយសារមូលហេតុមួយចំនួន ។ មានទ្រឹស្តីជាច្រើន ដែលអាចពន្យល់ពីមូលហេតុធ្វើឲ្យមនុស្សជ្រួលច្របល់ និងពីកត្តានាំឲ្យមនុស្សស្ថិតនៅលើស្ពានក្នុងរាត្រីនោះ មានក្តីព្រួយបារម្ភ ។ ជាឧទាហរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារិទ្ធ បានមានប្រសាសន៍ថា ឧបទ្ទវហេតុកកស្ទះ

ជាប់គ្នា បានចាប់ផ្តើមនៅពេលដែលមនុស្សភ្លាយជា "មានការភ័យខ្លាចនឹងអ្វីមួយ"[2] ។ ជុំវិញទ្រឹស្តីដែលអាចបកស្រាយពន្យល់បាន សាក្សីនិងសេចក្តីរាយការណ៍ពីសារព័ត៌មាន បានអះអាង ថាការជ្រួលច្របល់ត្រូវបានបង្កឡើងដោយ ៖ (១) រឿងរ៉ាវដែលថាស្ពានយោលកំពុងតែបាក់, (២) ការភ័យខ្លាចថាមនុស្សត្រូវបានខ្សែភ្លើងឆក់ ដែលប្រហែលមកពីកំហុសខាងជាក់ភ្លើងបំភ្លឺស្ពាន ឬពីហេតុដែលប៉ូលីសប្រើកាណុងបាញ់ទឹក ទៅលើក្រុមមហាជន, (៣) មនុស្សម្នាបានដួលសន្លប់ ដោយសារកំដៅ, ឬ (៤) ការវាយតប់គ្នាដែលកើតឡើងរវាងក្រុមក្មេងទំនើងពីរក្រុម ។ ការជ្រួលច្របល់ទំនងជាលទ្ធផល នៃកត្តាផ្សេងៗគ្នាជាច្រើន ហើយយើងនឹងពុំអាចដឹងអំពីលំដាប់ព្រឹត្តិការណ៍ពិតប្រាកដ របស់ឧបទ្ទវហេតុនេះឡើយ ។ ការជ្រួលច្របល់ និងឧបទ្ទវហេតុដែលជាលទ្ធផលនៃការជ្រួលច្របល់នេះ អាចគ្រាន់តែបណ្តាលមកពីមានមនុស្សច្រើនពេក ស្ថិតក្នុងទីចង្អៀតនៅលើស្ពាន ក៏ថាបាន ។

ក៏មានភាពមិនច្បាស់លាស់ផងដែរ ជុំវិញចំនួនអ្នកស្លាប់ ពីព្រោះថាតួលេខរាយការណ៍បានប្រែប្រួលយ៉ាងខ្លាំង នៅសប្តាហ៍ក្រោយឧបទ្ទវហេតុ ។ មូលហេតុចំពោះបម្រែបម្រួលនេះ រួមមាន ៖ មិត្តឬសាច់ញាតិបានយកសាកសពជនរងគ្រោះទៅផ្ទះ មុនពេលត្រូវបានចុះបញ្ជីឈ្មោះអ្នកស្លាប់[3], ក្រុមគ្រួសារអ្នកស្លាប់បានយកសាកសពជនរងគ្រោះ ចេញពីទីកើតហេតុ[4], មានស្ថិតិស្ទួនគ្នា[5], សាកសពខ្លះដែលស្លាប់ដោយសារមូលហេតុផ្សេង ត្រូវបានរាប់នៅឯមន្ទីរពេទ្យ[6], និងការរាប់បញ្ចូលអ្នកបាត់ខ្លួន[7] ។ កង្វះភាពច្បាស់លាស់នេះ ទំនងពុំមែនជាការបកស្រាយពន្យល់ត្រឹមត្រូវឡើយ ពីព្រោះគេអាចកំណត់បានច្បាស់លាស់ អំពីចំនួនមនុស្សរងគ្រោះក្នុងឧបទ្ទវហេតុ ។

មូលហេតុនៃការស្លាប់

មូលហេតុផ្សេងគ្នាជាច្រើននៃការស្លាប់ ត្រូវបានរាយការណ៍ក្រោយកើតសោកនាដកម្ម ហើយមូលហេតុទាំងនេះបានផ្លាស់ប្តូរ ខណៈដែលវេលាកន្លងហួសទៅ ។ បណ្តាមន្ទីរពេទ្យបានរាយការណ៍ ថាមូលហេតុចម្បងនៃការស្លាប់ គឺការថប់ដង្ហើម ការលង់ទឹក និងហូរឈាមក្នុងខ្លួន ។ ទោះជាយ៉ាងនេះក្តី សាក្សីនៃឧបទ្ទវហេតុ និងជនរងគ្រោះដែលរងរបួសនៅរាត្រីនោះ បាននិយាយដដែលៗ ថាអ្នកខ្លះត្រូវបានខ្សែភ្លើងឆក់ប្រហែលបណ្តាលមកពីភ្លើងអគ្គិសនីបំភ្លឺលើស្ពាន ។ សេចក្តីអត្ថាធិប្បាយពីបណ្តាវេជ្ជបណ្ឌិត ដែលម.ស.ម.ក បានសាកសួរ និងដែលបាននិយាយ ថាវេជ្ជបណ្ឌិតផ្សេងទៀតក្នុងមន្ទីរពេទ្យនេះ បានឃើញមនុស្សជាច្រើន

---

[2] សារព័ត៌មានឌឹញូវយ៉ែកថាមស៍ ចំណងជើង "ការរត់ជាន់គ្នានៅកម្ពុជាបានបណ្តាលឲ្យមនុស្សរាប់រយនាក់ស្លាប់" ចុះផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១០ ។

[3] សារព័ត៌មានអាសូស៊ីអេត ប្រែស ចំណងជើង "នគរបាលនិយាយថា គ្រោះថ្នាក់ផ្តើលរត់ជាន់គ្នា បណ្តាលមកពីការភ័យខ្លាចថាស្ពានបាក់" ចុះផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[4] សារព័ត៌មានឌឹខេមបូឌាដេលី ចំណងជើង "រដ្ឋាភិបាលបន្តយចំនួនសរុបផ្លូវការនៃអ្នកស្លាប់ដោយសារការរត់ជាន់គ្នានៅកោះពេជ្រ" ចុះផ្សាយថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[5] សារព័ត៌មានស៊ិនហួរ ចំណងជើង "រដ្ឋាភិបាលកម្ពុជាកាត់បន្តយចំនួនអ្នកស្លាប់ក្នុងការរត់ជាន់គ្នាទៅ ៣៤៦នាក់" ចុះផ្សាយថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[6] វិទ្យុសំឡេងសហរដ្ឋអាមេរិក (វីអូអេ) ចំណងជើង "ស្ពានមិនរឹងមាំគឺជាមូលហេតុដែលត្រូវបន្ទោសសម្រាប់ការស្លាប់នៅក្នុងការរត់ជាន់គ្នានៅកម្ពុជា" ចុះផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[7] សារព័ត៌មានឌឹខេមបូឌាដេលី ចំណងជើង "រដ្ឋាភិបាលបន្តយចំនួនសរុបផ្លូវការនៃអ្នកស្លាប់ដោយសារការរត់ជាន់គ្នានៅកោះពេជ្រ" ចុះផ្សាយថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១០, សារព័ត៌មានឌឹខេមបូឌាដេលី ចំណងជើង "ចំនួនអ្នកស្លាប់នៅកោះពេជ្រ និងជំនួយសប្បុរសកើនឡើងជំណាលគ្នា" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ស្លាប់ដោយការឆក់ខ្សែភ្លើងនោះ គឺជាក្តីបារម្ភដ៏ជាក់លាក់ ។ ក៏ប៉ុន្តែ មួយរយៈពេលខ្លីបន្ទាប់ពីសេចក្តីអត្ថាធិប្បាយជាសាធារណៈរួចមក ឧត្តមសេនីយ៍មួយរូបបានមកនិយាយ ទៅកាន់គណៈដឹកនាំមន្ទីរពេទ្យនេះ ហើយប្រាប់គ្រូពេទ្យកុំឲ្យលើកឡើង អំពីការស្លាប់ដោយសារការឆក់ខ្សែភ្លើង ។ ក៏មានសេចក្តីរាយការណ៍ផងដែរ ថាប៉ូលីសបានប្រើកាណុងបាញ់ទឹកទៅលើក្រុមមហាជន ។ ថ្វីបើពុំមានមូលហេតុច្បាស់លាស់ ចំពោះការបាញ់ទឹកនេះក្តី សមាជិកមួយរូបនៃ «ក្រុមអ្នកពន្លត់អគ្គីភ័យអូស្ត្រាលី ខាងអប់រំ និងផ្តល់ជំនួយអន្តរជាតិ (Australia Firefighters International Relief and Education, AFIRE)» បានឲ្យដឹងថា ទង្វើបាញ់ទឹកនេះទំនងជាវិធានការត្រឹមត្រូវមួយ នៅពេលមានមនុស្សជាច្រើន ត្រូវបានកកស្ទះជាប់គ្នាក្នុងទីចង្អៀត ។

រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធម្តងហើយម្តងទៀត ថាគ្មានមនុស្សស្លាប់ ដោយការឆក់ខ្សែភ្លើងនោះទេ ឬថាមានការប្រើប្រាស់កាណុងបាញ់ទឹកនោះក៏ទេដែរ ។

ជាការលំបាកដើម្បីកំណត់ ថាតើការឆក់ខ្សែភ្លើងឬចរន្តអគ្គិសនី ជាកត្តារួមចំណែកដល់គ្រោះថ្នាក់នេះឬយ៉ាងណាណាស់ ពីព្រោះថាគ្រោះថ្នាក់នោះផ្ទុំឡើង ដោយស្រទាប់ព្រឹត្តិការណ៍ផ្សេងគ្នាជាច្រើន ។ ម.ស.ម.កជឿជាក់ ថាឧបទ្ទវហេតុកោះពេជ្រ គួរត្រូវបានស៊ើបអង្កេតឡើងវិញ បំណងកំណត់ឲ្យច្បាស់អំពីឥទ្ធិពលនៃការប្រើប្រាស់ចរន្តអគ្គិសនី ប្រសិនកើតមានក្នុងករណីណាមួយនោះ ចំពោះការកួចផ្ទុំឡើងឲ្យមានឧបទ្ទវហេតុនេះ ។

ចំនួនខ្លះនៃសាក្សីដែលម.ស.ម.កសម្ភាស វេលាក្រោយមកក៏បានលើកអំពី "ជាតិពុលក្នុងឈាម" ថាជាមូលហេតុមួយនាំឲ្យបាត់បង់ជីវិតជនរងគ្រោះ ដែលរងរបួសក្នុងរាត្រីថ្ងៃ២២ខែកុម្ភៈនោះ ។ សេចក្តីពោលបែបនេះពុំត្រូវបានលើកឡើង ដោយរាជរដ្ឋាភិបាល ឬនៅក្នុងអត្ថបទកាសែតឡើយ ។ ម.ស.ម.កបានសាកសួរវេជ្ជបណ្ឌិតជាច្រើនរូប នៃមន្ទីរពេទ្យជុំវិញរាជធានីភ្នំពេញ ដែលបានមានប្រសាសន៍ ថាមូលហេតុចម្បងនៃការបាត់បង់ជីវិត គឺពាក់ព័ន្ធនឹងការស្ថិតក្នុងក្រុមមហាជនដ៏កកកុញយូរពេក ។ ក្នុងកាលៈទេសៈបែបនោះ កម្លាំងសង្កត់លើគ្នាឥតឈប់ អាចនាំដល់អាការៈហើមប៉ោង ហើយប្រសិនទុកចោលមិនព្យាបាល នឹងអាចធ្វើឲ្យដាច់សរសៃសាច់ដុំ និងរឹតត្បិតចរន្តឈាមរត់ ដែលជាលទ្ធផលចុងក្រោយ បណ្តាលឲ្យស្លាប់កោសិកាដោយសារកង្វះអុកស៊ីហ្សែន ។ ខណៈពេលសរសៃសាច់ដុំងាប់ សរសៃទាំងនោះក្លាយជាជាតិពុលដល់សារពាង្គកាយ និងប៉ះពាល់ដល់ប្រព័ន្ធប្រសាទ ។ ជាតិពុលនេះទៀតសោត នឹងបំផ្លាញសរីរៈថ្លើមនិងតម្រងនោម ហើយអាចបណ្តាលឲ្យជនរងគ្រោះមានអាការៈហើម និងនោមពុំចេញ ។ លើសពីនេះ ជនរងគ្រោះត្រូវបានជាប់កុនក្នុងក្រុមមនុស្សដ៏កកកុញ អស់រយៈពេលយ៉ាងយូរអំឡុងពេលកើតហេតុ ដែលការនេះធ្វើឲ្យខ្សោះកម្លាំងរំដោះខ្លួនចេញ និងខ្សោះជាតិទឹកពីខ្លួន ។ ការខ្សោះជាតិទឹកនេះ ក៏នាំឲ្យប៉ះពាល់តម្រងនោមដែរ ។ ក្នុងករណីបែបនេះ ជនរងគ្រោះត្រូវតែឲ្យគេលាងសម្អាតឈាមរបស់ខ្លួន ដោយប្រើវិធីសាស្ត្រឌីយ៉ាលីហ្ស៊ីស (dialysis) ។

ថ្វីបើយ៉ាងនេះ ប្រសិនបើសាធារណជន (ហើយពិសេស វេជ្ជបណ្ឌិត) ពុំបានដឹងពីអាការៈនេះទេ ទំនងដូចដែលឃើញមានការកាន់ច្រឡំ ចេញពីអត្ថបទរាយការណ៍សារព័ត៌មាន និងពីការរាប់រៀបអំពីការរងរបួសរបស់សាក្សី នោះជនរងគ្រោះនឹងបន្តបាត់បង់ជីវិត ពីការរងរបួសក្រោយកើតឧបទ្ទវហេតុដូច្នោះ ។ ជាការសំខាន់ណាស់ ដែលអាជ្ញាធរនិងសាធារណជន យល់ដឹងអំពីអាការៈទាំងនេះ ហើយត្រូវបានពន្យល់ប្រាប់ និងត្រូវបានបំពាក់ឧបករណ៍ព្យាបាលឲ្យបានត្រឹមត្រូវ ។

ទឹកប្រាក់សំណង

ចំនួនទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ត្រូវបានផ្តល់ជូនជាសប្បុរសធម៌ ពីសំណាក់សាធារណជន ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋាភិបាល ដែលការនេះបានបង្ហាញពីទំហំប៉ះពាល់នៃសោកនាដកម្មនេះ ចំពោះសាធារណជនកម្ពុជា ។ ជាសរុប លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា គ្រួសារជនរងគ្រោះដែលបាត់បង់ជីវិត នីមួយៗនឹងត្រូវទទួលបានទឹកប្រាក់ យ៉ាងហោចណាស់ចំនួន ១២.០០០ ដុល្លារអាមេរិក បានមកពីប្រភពផ្សេងៗជាច្រើន ។[8] សេចក្តីរាយការណ៍ឯទៀតបានអះអាង ថាគ្រួសារសពជនរងគ្រោះអាចទទួលបានទឹកប្រាក់ ដល់ទៅចំនួន ១២.២៥០ ដុល្លារអាមេរិក (ដោយចំនួនចុងក្រោយនេះ គឺអាស្រ័យលើទឹកប្រាក់សល់ពីការបែងចែកជូនដល់ជនរងគ្រោះដែលរងរបួស) ហើយថាទឹកប្រាក់សប្បុរសធម៌ទាំងអស់ ឈានដល់ចំនួន ៤ លាន ដុល្លារអាមេរិកឯណោះ ។[9] នេះជាចំនួនទឹកប្រាក់ដ៏សន្ធឹក បើធៀបនឹងចំណូលមធ្យមរបស់គ្រួសារកម្ពុជា ហើយវាបានបង្ហាញអំពីជម្រៅ នៃក្តីរន្ធត់ចិត្តឥតឧបមារបស់សាធារណជន ចំពោះសោកនាដកម្មមួយនេះ ។

ទោះជាយ៉ាងនេះ អត្ថបទរាយការណ៍សារព័ត៌មាន ដែលបរិយាយអំពីសប្បុរសជន ចំនួនទឹកប្រាក់សប្បុរសធម៌ និងអ្នកទទួលបានទឹកប្រាក់នេះ មានភាពច្របូកច្របល់ច្រើន ។ ម.ស.ម.កពុំអាចផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់សប្បុរសធម៌សរុប ឬទឹកប្រាក់សន្យាផ្តល់ជូនជនរងគ្រោះនីមួយៗ នៃឧបទ្ទវហេតុកកស្ទះជាប់គ្នា បាននោះទេ ដោយហេតុថា ៖ ព័ត៌មានដែលបានរាយការណ៍មានលក្ខណៈជាន់គ្នា ហើយសេចក្តីរាយការណ៍នោះទៀតសោត ពុំបានបែងចែកច្បាស់លាស់ រវាងការទទួលបានទឹកប្រាក់សន្យាផ្តល់ជូន ឬប្រាក់សប្បុរសធម៌ថ្មី និងការបែងចែកទឹកប្រាក់សប្បុរសធម៌មុនៗ ហើយពុំបានរាយការណ៍ពីចំនួនទឹកប្រាក់សរុបចុងក្រោយ ដែលគ្រួសារជនរងគ្រោះទាំងអស់ទទួលបាន ក្រៅតែអំពីទឹកប្រាក់ទទួលបាន ក្នុងថ្ងៃជាក់លាក់ណាមួយនោះ ។

លើសនេះទៀត បើតាមមនុស្សដែលម.ស.ម.កបានសម្ភាស មិនមែនគ្រប់ជនរងគ្រោះទាំងអស់ សុទ្ធតែបានទទួលទឹកប្រាក់សន្យាគ្រប់ចំនួនឡើយ នេះគិតមកត្រឹមពេលសម្ភាសន៍ ។ គេគួរកត់សម្គាល់ថា កិច្ចសម្ភាសន៍របស់ម.ស.ម.កត្រូវបានធ្វើឡើង ភ្លាមបន្ទាប់ពីមានព្រឹត្តិការណ៍នោះ ហើយថាគ្រួសារជនរងគ្រោះទាំងនោះ ប្រហែលបានទទួលទឹកប្រាក់សប្បុរធម៌ គ្រប់តាមចំនួនដែលបានសន្យាហើយ អំឡុងពេលក្រោយមកទៀត ។

ម.ស.ម.កពុំបានធ្វើការវាយតម្លៃជាលម្អិត អំពីចំនួនទឹកប្រាក់សំណង ដែលត្រូវបានផ្តល់ឲ្យ និងដែលគ្រួសារជនរងគ្រោះនីមួយៗទទួលបាននោះឡើយ ។ ទោះជាយ៉ាងនេះក្តី តាមរយៈព័ត៌មានដែលម.ស.ម.កប្រមូលបានពីកិច្ចសម្ភាសន៍ ភ្លាមបន្ទាប់ពីកើតសោកនាដកម្ម និងតាមសេចក្តីរាយការណ៍របស់ប្រភពសារព័ត៌មាននាពេលនោះ ទំនងជាមិនមានជនរងគ្រោះគ្រប់រូបនៃឧបទ្ទវហេតុ ដែលមានសិទ្ធិទទួលបានប្រាក់សំណង សុទ្ធតែទទួលបានប្រាក់សំណងទាំងនោះ ឬថាយ៉ាងហោចណាស់ទទួលបានសំណង

[8] សារព័ត៌មានអាសូស៊ីអេត ប្រៃស ចំណងជើង "នាយករដ្ឋមន្ត្រីកម្ពុជានិយាយថានឹងគ្មានការដាក់ទោសទណ្ឌ ដោយសារការស្លាប់ក្នុងគ្រោះថ្នាក់ផ្តើលជាន់គ្នានោះទេ" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០, សារព័ត៌មានស៊ិនហួរ ចំណងជើង "ជនរងគ្រោះនៃការរត់ជាន់គ្នានៅកម្ពុជាទទួលប្រាក់ឧបត្ថម្ភពី មូលនិធិស្ថានីយទូរទស្សន៍" ចុះផ្សាយថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ។

[9] សារព័ត៌មានឌឺខេមបូឌាដេលី ចំណងជើង "ចំនួនអ្នកស្លាប់នៅកោះពេជ្រ និងជំនួយសប្បុរសកើនឡើងជំណាលគ្នា" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

គ្រប់ចំនួនទឹកប្រាក់សន្យាផ្តល់ជូននោះទេ ។ គ្រួសារជនរងគ្រោះក៏ទទួលបានព័ត៌មានមិនពេញលេញ អំពីទីកន្លែងនិងរបៀបរបប បើកប្រាក់សំណងនោះដែរ ។ ជនរងគ្រោះគួរតែអាចទទួល ចំណែកនៃប្រាក់សំណងរបស់ខ្លួន បានយ៉ាងងាយស្រួល ប្រសិនបើទឹកប្រាក់សំណងសប្បុរសធម៌ ត្រូវបានចាត់ចែងប្រកបដោយភាពច្បាស់លាស់ និងតម្លាភាព ។ រាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ ពិនិត្យមើលឡើងវិញនូវសកម្មភាពប្រគល់ជូនប្រាក់សំណងនេះ តាមរយៈការចូលរួមជួយ ប្រសិនបើចាំបាច់ ពីសំណាក់ធនាគារអេស៊ីលីដា ដែលជាអ្នកបើកគណនីឲ្យជនរងគ្រោះ សម្រាប់សម្រួលដល់ការចែកចាយទឹកប្រាក់សំណង និងដោយហេតុនេះហើយ គឺជាអ្នកដែលមានកំណត់ត្រាអំពីប្រតិបត្តិការប្រគល់ទឹកប្រាក់សំណងនេះ បំណងបញ្ជាក់ឲ្យបានច្បាស់ ថាតើទឹកប្រាក់សំណងត្រូវបានចែកចាយត្រឹមត្រូវឬយ៉ាងណា ។

ចំណាត់ការរបស់រាជរដ្ឋាភិបាល

មន្ត្រីរដ្ឋាភិបាល ដែលមានកម្រិតសមត្ថកិច្ចផ្សេងៗគ្នា រាប់ចាប់តាំងពីលោកអភិបាលរាជធានីភ្នំពេញ ទៅដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តីអត្ថាធិប្បាយ នៅប៉ុន្មានថ្ងៃនិងសប្តាហ៍ ក្រោយកើតឧបទ្ទវហេតុកកស្ទះជាប់គ្នា ។ រាជរដ្ឋាភិបាលហាក់បានបដិសេធចោលភ្លាមៗ ចំពោះការទទួលខុសត្រូវលើឧបទ្ទវហេតុកកស្ទះជាប់គ្នា ក៏ប៉ុន្តែប្រតិកម្មតបនោះ មានលក្ខណៈចម្រុះនិងភាន់ច្រឡំ នេះរាប់ទាំងតួលេខដ៏ចម្រូងចម្រាសនៃអ្នកស្លាប់ ឥរិយាបថទំនងជាទទួលយកការស្តីបន្ទោស និងការបដិសេធចោលវេលាក្រោយមកចំពោះការទទួលខុសត្រូវ ។ ព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០១០ ទំនងជាមានលក្ខណៈឱឡារិក ជាងឆ្នាំកន្លងមក ។ ក៏ប៉ុន្តែ កិច្ចការងាររៀបចំសម្រាប់ពិធីបុណ្យលើកនេះ បានផ្តោតតែទៅលើការលង់ទឹក និងអំពើចោរកម្ម ជាជាងទៅលើការគ្រប់គ្រងក្រុមមហាជន ។ អ្នកនាំពាក្យខ្លះបានទទួលស្គាល់ ចំពោះកង្វះខាតមួយចំនួនដុំវិញការរៀបចំរបស់អាជ្ញាធរមានសមត្ថកិច្ច ។ ជាឧទាហរណ៍ រាជរដ្ឋាភិបាលបានទទួលស្គាល់ ថាខ្លួនបានមើលស្រាល ទៅលើបញ្ហាគ្រប់គ្រងក្រុមមហាជនចូលរួមក្នុងពិធីបុណ្យ ៖ "យើងមានការព្រួយបារម្ភអំពីបញ្ហាដែលទូកអាចក្រឡាប់លិច និងការឆក់ហោប៉ៅ...យើងពុំបានគិត អំពីការកើតឡើងឧបទ្ទវហេតុបែបនេះឡើយ" នេះជាប្រសាសន៍ របស់លោករដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កាញារិទ្ធ[10] ។ ទោះជាយ៉ាងនេះក្តី គ្មាននរណាម្នាក់ ចេញមុខទទួលយកទំនួលខុសត្រូវ ចំពោះការកើតមានព្រឹត្តិការណ៍សោកនាដកម្មនោះទេ ហើយរដ្ឋាភិបាលនៅតែរក្សាជំហររបស់ខ្លួន ថាវាជាឧបទ្ទវហេតុដែលមិនអាចរំពឹងទុកមុនបាន ។

ក៏មានសេចក្តីអត្ថាធិប្បាយផងដែរ នៅក្នុងអត្ថបទសារព័ត៌មាន ទាក់ទិននឹងចំណាត់ការសង្គ្រោះបន្ទាន់ក្នុងឧបទ្ទវហេតុកកស្ទះជាប់គ្នា ។ ទាំងនេះបង្ហាញពីការយល់ឃើញខុសៗគ្នា ជុំវិញលក្ខណៈគ្រប់គ្រាន់នៃចំណាត់ការសង្គ្រោះបន្ទាន់ និងចំណាត់ការរបស់ប៉ូលីស នៅរាត្រីមួយនោះ ។ សេចក្តីអត្ថាធិប្បាយទាំងនោះបានស្នើឡើង ថាចំណាត់ការសង្គ្រោះបន្ទាន់នឹងមានលក្ខណៈគ្រប់គ្រាន់ ល្តឹកណាទំហំនិងភាពធ្ងន់ធ្ងរនៃឧបទ្ទវហេតុ ត្រូវបានគេមើលឃើញ ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការសិទ្ធិមនុស្សអាស៊ី បានបូកសរុបសភាពការណ៍ ដោយនិយាយថា ៖ "ថ្វីត្បិតមូលហេតុពិតប្រាកដនៃឧបទ្ទវហេតុផ្តើលជាន់គ្នាកាលពីយប់ម្សិលមិញ នៅមានភាពពុំច្បាស់លាស់ ពីហេតុនៃលក្ខណៈចម្រូងចម្រាស់ ជុំវិញសេចក្តីរាយការណ៍ ដែលគួសបញ្ជាក់ថាវាបណ្តាល ឬមួយមកពីការលេងសើចរបស់ក្រុមមហាជន ឬមួយក៏មកពីសំណង់ស្ពានទៅកាន់កោះ

[10] អេជិន ហ្រ្វង់ ប្រែស (អាអែសប៉េ) ចំណងជើង "ភាពខឹងសម្បារកើនឡើង ខណៈពេលដែលតួលេខអ្នកស្លាប់ពីការកកជាប់ស្ទះកើនឡើង" ចុះផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ពេជ្រមិនមានគុណភាពល្អយ៉ាងណាក្តី ក៏គេឃើញច្បាស់ ថារដ្ឋបរាជ័យក្នុងការគ្រប់គ្រងក្រុមមហាជន និងកម្រិតការខូចខាតពីឧបទ្ទវហេតុផ្តើលជាន់គ្នា" ។[11]

យ៉ាងហោចណាស់ជាការជាក់ច្បាស់នោះគឺថា គេត្រូវតែអនុវត្តវិធានការល្អិតល្អន់ជាងមុន និងមានផែនការស៊ើជម្រៅជាងមុន ដើម្បីជៀសវាងស្ថានការណ៍ស្រដៀងគ្នា កើតឡើងបាននៅពេលក្រោយទៀត ។

ទាក់ទិននឹងសេចក្តីរាយការណ៍ ដែលទំនងបានលេចឡើងក្នុងប្រព័ន្ធផ្សព្វផ្សាយ បន្ទាប់ពីសេចក្តីសន្និដ្ឋានរបស់គណៈកម្មការស៊ើបអង្កេតត្រូវបានប្រកាសរួចនោះ បានឲ្យដឹងថា អាជ្ញាធរបានទប់ស្កាត់ការលក់ស៊ីឌី ដែលផ្ទុកខ្សែភាពយន្តនៃឧបទ្ទវហេតុកកស្ទះជាប់គ្នា ។ លោក ថៃ នរៈសត្យា រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានប្រសាសន៍ថា ក្រុមការងារក្រសួងនិងប៉ូលីស រឹបអូសបានវីស៊ីឌីជាច្រើនបន្ទះ ពីអ្នកលក់ទៅតាមបណ្តាខេត្តនានានៅទូទាំងប្រទេស ។[12] ខ្សែវីដេអូនោះត្រូវបានគេរាយការណ៍ ថាមានផ្ទុកភាពយន្តរយៈពេលមួយម៉ោង អំពីព្រឹត្តិការណ៍កកស្ទះជាប់គ្នានោះ ដែលទទួលបានពីប្រព័ន្ធផ្សព្វផ្សាយទាំងក្នុងនិងក្រៅស្រុក ដោយមានបង្ហាញនូវសកម្មភាពជួយសង្គ្រោះ ក្រុមគ្រួសារស្វែងរកសាច់ញាតិរបស់ខ្លួន និងពិធីកាន់ទុក្ខដែលចូលរួមដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ចំណាត់ការបង្ក្រាបការលក់ស៊ីឌីនេះ ហាក់បង្ហាញថា អាជ្ញាធររាជរដ្ឋាភិបាល ព្យាយាមរាំងខ្ទប់ការផ្សាយព័ត៌មាន អំពីឧបទ្ទវហេតុកកស្ទះជាប់គ្នា ។

គណៈកម្មការរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការជាច្រើន ដើម្បីស៊ើបអង្កេតឧបទ្ទវហេតុកកស្ទះជាប់គ្នា និងសម្របសម្រួលចំណាត់ការឆ្លើយតប ។ សមាសភាពគណៈកម្មការរបស់រាជរដ្ឋាភិបាល ត្រូវបានរិះគន់យ៉ាងខ្លាំង ពីព្រោះគណៈកម្មការទាំងនេះ ត្រូវបានគ្របដណ្តប់មួយភាគធំ ដោយសមាសភាពមន្ត្រីរាជរដ្ឋាភិបាល និងអ្នកដែលពាក់ព័ន្ធចំពោះការកើតមានឧបទ្ទវហេតុ (ដូចជាមន្ទីរពេទ្យ និងអ្នកអភិវឌ្ឍន៍កោះពេជ្រ) ។ ជាឧទាហរណ៍ អ្នកនាំពាក្យរបស់គណបក្សសមរង្ស៊ី លោក យឹម សុវណ្ណ បាននិយាយ ថាគាត់មានជំនឿចិត្តតិចតួចចំពោះគណៈកម្មការ ក្នុងការដាក់ឲ្យមន្ត្រីណាម្នាក់ទទួលខុសត្រូវ ៖ "មនុស្សនៅក្នុងគណៈកម្មការនេះគឺជាមនុស្សតែមួយដែលរៀបចំព្រឹត្តិការណ៍...ដូចនេះខ្ញុំមិនគិតថានេះនឹងឯករាជ្យទេ" ។[13] លោក ខៀវ កាញារិទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បាននិយាយ ថាគណៈកម្មការមានសុទ្ធតែមន្ត្រីរដ្ឋាភិបាល ដោយសារគណៈកម្មការនេះត្រូវបានបង្កើតឡើង នៅវេលាម៉ោង ១ ព្រឹក បន្ទាប់ពីរាត្រីកើតហេតុ ៖ "យើងមិនរំពឹងថាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ធ្វើការនោះឡើយនាវេលាម៉ោងនេះ" ។[14]

សេចក្តីសន្និដ្ឋានរបស់គណៈកម្មការ ត្រូវបានធ្វើឡើង ត្រឹមតែមួយសប្តាហ៍ក្រោយសោកនាដកម្មប៉ុណ្ណោះ ហើយលទ្ធផលនៃការរកឃើញរបស់គណៈកម្មការទៀតសោត ត្រូវបានបង្ហាញក្នុងពេលសន្និសីទ

---

[11] គណៈកម្មការសិទ្ធិមនុស្សអាស៊ាន ចំណងជើង "កម្ពុជា ៖ គណកម្មការសិទ្ធិមនុស្សអាស៊ានបង្ហាញពីភាពអាណិតអាសូរ និងអំពាវនាវឲ្យមានការស៊ើបអង្កេតចំពោះសោកនាដកម្មនេះ" ផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[12] សារព័ត៌មានភ្នំពេញប៉ុស្ត៍ ចំណងជើង "ខ្សែវីដេអូរកោះពេជ្រត្រូវបានបង្ក្រាប" ចុះផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ។

[13] សារព័ត៌មានឌឺខេមបូឌាដេលី ចំណងជើង "រដ្ឋាភិបាលចេញផ្សាយព័ត៌មានបន្តិចបន្តួចជុំវិញការស៊ើបអង្កេតពីសោកនាដកម្ម" ចុះផ្សាយថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[14] សារព័ត៌មានឌឺខេមបូឌាដេលី ចំណងជើង "រដ្ឋាភិបាលរកជំនួយពីសាធារណជនក្នុងការស៊ើបពីការរត់ជាន់គ្នា" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

សារព័ត៌មាន ប្រារព្ធធ្វើនៅទីស្តីការគណៈរដ្ឋមន្ត្រី នារសៀលថ្ងៃទី២៩ ខែវិច្ឆិកា ។[15] គណៈកម្មការចម្បងបានបញ្ជាក់ជំហររបស់រាជរដ្ឋាភិបាល ថាឧបទ្ទវហេតុបានកើតចេញពីការភ័យស្លន់ស្លោក្នុងទ្រង់ទ្រាយធំ ទាក់ទងនឹងរំយោលរបស់ស្ពាន ដែលភ្ជាប់ទៅកាន់កោះពេជ្រ ៖ "មិនមានសញ្ញាគេវេកម្ម ឬឧក្រិដ្ឋកម្មគ្រោងទុកជាមុននោះទេ ។ យើងអាចនិយាយបាន ថារឿងនេះកើតឡើងដោយសារការរត់ជាន់គ្នា" ។[16] ក្រៅអំពីព័ត៌មានលម្អិតនៃសន្និសីទកាសែតនេះ ម.ស.ម.កមិនអាចស្វែងរកបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលបានដាក់ចេញដោយគណៈកម្មការនោះទេ ។

រាជរដ្ឋាភិបាលបានសន្និដ្ឋាន ថារឿងនោះជាឧបទ្ទវហេតុ ហើយនៅទីបញ្ចប់ គ្មាននរណាម្នាក់ត្រូវបានស្តីបន្ទោស តម្រូវឲ្យលាលែងពីដំណែង ឬយកមកកាត់ទោសនោះទេ ។[17] ភ្លាមបន្ទាប់ពីកើតសោកនាដកម្ម គណបក្សប្រឆាំងនិងបណ្តាអង្គការសង្គមស៊ីវិល អំពាវនាវឲ្យលោក កែប ជុតិមា អភិបាលរាជធានីភ្នំពេញ និងលោក ទូច ណារ៉ុថ ស្នងការប៉ូលីសរាជធានី ចុះចេញពីដំណែង ។[18] ស្របពេលដែលគណៈកម្មការ ប្រកាសរបកគំហើញរបស់ខ្លួន ចំពោះបុព្វហេតុនៃការកកស្ទះជាប់គ្នានោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា គ្មានមន្ត្រីណាមួយត្រូវបានដាក់បន្ទុកឲ្យទទួលខុសត្រូវ លើរឿងនេះទេ ហើយការអំពាវនាវឲ្យមន្ត្រីជាន់ខ្ពស់ចុះចេញពីតំណែងនោះ គឺជារឿងនយោបាយ ។ ទោះជាយ៉ាងនេះក្តី លោក ហ៊ុន សែន បានថ្លែងថា ៖ ព្រឹត្តិការណ៍ដែលបានកើតឡើងនេះ បិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាល... ឧបទ្ទវហេតុនេះកើតឡើងដោយសារភាពធ្វេសប្រហែស ហើយយើងមិនបានរំពឹង ថារឿងបែបនេះនឹងអាចកើតឡើង...កំហុសដ៏ធំបំផុតនោះ គឺថាយើងមិនយល់ពីស្ថានការណ៍ទាំងស្រុង" ។[19] "នេះគឺជាកំហុសរួមដែលធ្វើឲ្យកើតព្រឹត្តិការណ៍បែបនេះ...រឿងនេះគឺយើងមិនបានរំពឹងទុក ហើយយើងធ្វេសប្រហែស...ហើយមិនបានរៀបចំវិធានការការពារជាមុន" ។[20] លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានអះអាងថា លោក គង់ សំអុល ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិនិងអន្តរជាតិ បានស្នើលាលែងពីមុខដំណែង ប៉ុន្តែត្រូវបានគាត់បដិសេធ ។[21]

---

[15] ព័ត៌មានកម្ពុជាទាន់ហេតុការណ៍ ចំណងជើង "លទ្ធផលនៃការស៊ើបអង្កេតលើស្ពានពេជ្រ ៖ បង្ហាញថាជាឧបទ្ទវហេតុសុទ្ធសាធ [ដូចជាការអះអាងរបស់រដ្ឋាភិបាល] ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០, សារព័ត៌មានឌីខេមបូឌាដេលី ចំណងជើង "លោក ហ៊ុន សែន បដិសេធមិនឲ្យនិយាយពីការលាឈប់ពាក់ព័ន្ធនឹងកោះពេជ្រ" ចុះផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[16] សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចំណងជើង "ចូលរួមទទួលកំហុសក្នុងសោកនាដកម្ម" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[17] វ៉ែបសាយរបស់សាលារាជធានីភ្នំពេញ (www.phnompenh.gov.kh) "ឧបទ្ទវហេតុកាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ គឺជាឧបទ្ទវហេតុកើតឡើងដោយចៃដន្យ" ចុះផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[18] វ៉ែបសាយ *Everyday.com.kh* ចំណងជើង "គណបក្សប្រឆាំង ៖ លោក កែប ជុតិម៉ា និង លោក ទូច ណារ៉ុថ គួរតែចុះចេញពីតំណែង" ចុះផ្សាយថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[19] សារព័ត៌មានប៊ីប៊ីស៊ី ចំណងជើង "នាយករដ្ឋមន្ត្រីកម្ពុជានិយាយថាគ្មាននរណាត្រូវទទួលខុសត្រូវចំពោះគ្រោះថ្នាក់ផ្តើលរត់ជាន់គ្នានេះទេ" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[20] សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចំណងជើង "ចូលរួមទទួលកំហុសក្នុងសោកនាដកម្ម" ចុះផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

[21] សារព័ត៌មានឌីខេមបូឌាដេលី ចំណងជើង "លោក ហ៊ុន សែន បដិសេធមិនឲ្យនិយាយពីការលាឈប់ពាក់ព័ន្ធនឹងកោះពេជ្រ" ចុះផ្សាយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

ការទទួលខុសត្រូវ និងភាពឆ្វេសប្រហែស

មានសេចក្តីរាយការណ៍ អំពីសេចក្តីព្រាងច្បាប់មួយ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលអាចនឹងសមស្របសម្រាប់អនុវត្ត ក្នុងព្រឹត្តិការណ៍គ្រោះថ្នាក់នានា ដែលអាចកើតឡើងនៅពេលអនាគត ។ មានបញ្ញត្តិដែលទើបនឹងអនុម័តថ្មីៗ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ (កាត់ថា «ក្រមរដ្ឋប្បវេណី») ដែលមានចែងអំពីការទទួលខុសត្រូវ និងសំណងលើការខូចខាត ចំពោះករណីបាត់បង់មិនមែនសេដ្ឋកិច្ច និងការបាត់បង់ជីវិតដោយកំហុសឆ្គង និងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ (កាត់ថា «ក្រមព្រហ្មទណ្ឌ») ដែលមានចែងអំពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។ គ្មានបញ្ញត្តិណាមួយ ក្នុងចំណោមបញ្ញត្តិទាំងនេះ បានចូលជាធរមាន នៅពេលឧបទ្ទវហេតុនេះកើតឡើងនោះទេ ។

ម.ស.ម.កស្វាគមន៍ចំពោះបញ្ញត្តិថ្មីៗនេះ ហើយសង្ឃឹមថាច្បាប់ថ្មីទាំងនេះ នឹងរួមចំណែកអភិវឌ្ឍវប្បធម៌គណនេយ្យភាព ចំពោះព្រឹត្តិការណ៍ដូចករណីកោះពេជ្រ ។ ទោះជាយ៉ាងនេះក្តី ម.ស.ម.កបារម្ភថានឹងគ្មាននរណាម្នាក់ទទួលខុសត្រូវ ចំពោះសោកនាដកម្មកោះពេជ្រ ក្រោមបញ្ញត្តិដែលបានចូលជាធរមាននាពេលព្រឹត្តិការណ៍នេះកើតឡើងនោះទេ ពោលគឺច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ (កាត់ថា «ច្បាប់អ៊ិនតាក់») ។

ម.ស.ម.កជឿជាក់ ថាយន្តការដែលត្រូវបានចែងក្នុងច្បាប់ គួរត្រូវបានអនុឡោមតាម ដើម្បីជានាថានីតិរដ្ឋត្រូវបានគោរព និងថាជនរងគ្រោះនៃសោកនាដកម្ម ត្រូវបានផ្តល់សំណងសមស្រប ។ ប្រសិនបញ្ញត្តិពាក់ព័ន្ធ ដែលបានចូលធរមានហើយ ពុំត្រូវបានអនុវត្តក្នុងការនាំអ្នកពាក់ព័ន្ធឲ្យមកទទួលខុសត្រូវទេ នោះបញ្ញត្តិថ្មីៗនឹងមិនទំនងត្រូវបានអនុវត្តដូចគ្នា ចំពោះករណីសោកនាដកម្ម ដែលអាចកើតមាននាពេលអនាគត ។ ជាអនុសាសន៍ គួរមានការស៊ើបអង្កេតឯករាជ្យដ៏ពេញលេញមួយ ចំពោះករណីកោះពេជ្រ ហើយបន្ទាប់ពីចេញលទ្ធផលស៊ើបអង្កេតរួច គេគួរប្រើប្រាស់នីតិវិធីច្បាប់នានា ដែលស្ថិតនៅធរមានក្នុងពេលកើតហេតុ ។ ការបង្កើតច្បាប់ថ្មីពុំគ្រប់គ្រាន់នោះទេ សម្រាប់កសាងប្រព័ន្ធច្បាប់ដ៏យុត្តិធម៌ ។ ជាជំនួសវិញ គួរមានការផ្លាស់ប្តូរឥរិយាបថរបស់អ្នកកាន់អំណាច ឲ្យមានឆន្ទៈទទួលយកទំនួលខុសត្រូវដ៏ពិតប្រាកដ ចំពោះព្រឹត្តិការណ៍សោកសៅ ដូចករណីកោះពេជ្រជាដើម ។

សេចក្តីសន្និដ្ឋាន

ដោយយោងលើភាពមិនច្បាស់លាស់និងយល់ច្រឡំ ជុំវិញអង្គហេតុនៃឧបទ្ទវហេតុនេះ ម.ស.ម.កផ្តល់អនុសាសន៍ ឲ្យមានការបើកការស៊ើបអង្កេតឡើងវិញ និងបង្កើតជាសំណួរបន្ថែមទៀត ដើម្បីកំណត់ឲ្យឃើញ នូវរឿងរ៉ាវកើតឡើងក្នុងរាត្រីនោះ ។ ជ្បិតម.ស.ម.កពុំលើកឡើង ថាបុគ្គលឬស្ថាប័នជាក់លាក់ណាមួយ គួរត្រូវបានស្តីបន្ទោស និងថាបុគ្គលជាក់លាក់រូបណាមួយ គួរលាលែងចុះពីដំណែងក្តី ម.ស.ម.កយល់ឃើញ ថាគួរមានកម្រិតទំនួលខុសត្រូវខ្ពស់ជាងនេះ ចំពោះឧបទ្ទវហេតុមួយនេះ ។ ប្រហែលជាសំខាន់ជាងនេះទៀតនោះ គឺថាគួរមានកិច្ចពិភាក្សាដ៏ហ្មត់ចត់មួយ អំពីវិធានការនិងប្រព័ន្ធគ្រប់គ្រង ដែលគួរត្រូវបានអនុវត្ត ដើម្បីកាត់បន្ថយឱកាសនៃការកើតមានឡើង នូវព្រឹត្តិការណ៍ស្រដៀងគ្នានេះ នៅពេលអនាគត ។ ប្រសិនបើរាជរដ្ឋាភិបាលទទូចអះអាង ថានេះជាគ្រោះថ្នាក់ដែលមិនមានកំហុស នោះនឹងមានហានិភ័យដ៏

ជាក់ច្បាស់ ដែលព្រឹត្តការណ៍ស្រដៀងគ្នានេះនឹងអាចមានកើតឡើងទៀត នៅក្នុងពិធីបុណ្យជាតិនានា ទៅថ្ងៃខាងមុខ ។

តាមរយៈលទ្ធផលដែលម.ស.ម.កបានរកឃើញ គណៈកម្មការពិសេសហាក់ពុំបានផ្តល់អនុសាសន៍ជាក់លាក់ សម្រាប់ឲ្យអនុវត្តក្នុងពិធីបុណ្យនានា ទៅថ្ងៃអនាគតឡើយ ។ ម.ស.ម.កមានសំណួរសំខាន់ៗមួយចំនួន ជុំវិញរបៀបរបបរៀបចំព្រឹត្តិការណ៍បុណ្យជាតិ នាពេលអនាគត ។ ម.ស.ម.កក៏មានក្តីបារម្ភផងដែរ ថាអាជ្ញាហាក់ពុំបានយល់ច្បាស់ អំពីភាពធ្ងន់ធ្ងរនៃសោកនាដកម្មនេះ ហើយនឹងបន្តគ្រប់គ្រងព្រឹត្តិការណ៍ទាំងនេះ ទៅតាមអ្វីដែលគាត់ធ្លាប់អនុវត្តកន្លងមក ។ មុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ នៅខែមេសា ឆ្នាំ ២០១១ ដែលជាថ្ងៃឈប់សម្រាកបុណ្យជាតិ បន្ទាប់ពីថ្ងៃបុណ្យអុំទូកនៅខែវិច្ឆិកា ឆ្នាំ២០១០ មានការរាយការណ៍ ថាមេប៉ូលីសសង្កាត់ចតុមុខ បានស្នើឲ្យម្ចាស់អាជីវកម្មទាំងអស់ផ្តល់គ្រឿងកេសជ្ជៈ ដល់ប៉ូលីសដែលកំពុងបំពេញភារកិច្ចក្នុងពេលបុណ្យ ។[22] ថ្វីបើលោក ទូច ណារ៉ុថ ស្នងការប៉ូលីសរាជធានី បានអះអាងថាមន្ត្រីប៉ូលីសមិនត្រូវបានអនុញ្ញាតឲ្យសេពគ្រឿងស្រវឹង ក្នុងពេលបំពេញភារកិច្ចក៏ដោយ ការស្នើបែបនេះឆ្លុះបញ្ចាំង ពីការមិនគោរពសារៈសំខាន់នៃតួនាទីរបស់ប៉ូលីស ក្នុងការគ្រប់គ្រងក្រុមមហាជននៅពិធីបុណ្យធំៗ និងធ្វើការដើម្បីបញ្ចៀសគ្រោះមហន្តរាយនានានោះឡើយ ។

ជាការគួរឲ្យកត់សម្គាល់ គឺថាការប្រណាំងទូកក្នុងព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០១១ ត្រូវបានលុបចោល ។[23] ការលុបចោលនេះត្រូវបានរាយការណ៍ ថាបណ្តាលមកពីទឹកជំនន់ធំនៅក្នុងប្រទេស ។ ពុំមានភាពច្បាស់លាស់ ថាតើកត្តានាំឲ្យមានការសម្រេចចិត្តនេះ មកពីឧបសគ្គនៃលទ្ធភាពរបស់អាជ្ញាធរ ក្នុងការដោះស្រាយឲ្យបានត្រឹមត្រូវ ជាមួយក្រុមមហាជនដ៏ធំបែបនោះ ឬយ៉ាងណាឡើយ ។ ទោះជាមូលហេតុអ្វីក៏ដោយ ដែលនៅពីក្រោយសេចក្តីសម្រេចចិត្តនេះ ម.ស.ម.កជឿជាក់ ថាវាជាជំហានប្រកបដោយទំនួលខុសត្រូវមួយសម្រាប់រាជរដ្ឋាភិបាល ក្នុងទេសៈកាលៈបែបនេះ ។

មុនពេលប្រារព្ធព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០១១ រាជរដ្ឋាភិបាលបានបង្ហាញឲ្យឃើញ អំពីចំណុចវិជ្ជមាន ថ្វីបើពុំមានលក្ខណៈជាក់លាក់ ចំពោះការរៀបចំវិធានការគ្រប់គ្រងក្រុមមហាជន ។[24] ម.ស.ម.កយល់ថា សកម្មភាពទាំងនេះជាជំហានវិជ្ជមាន ក្នុងការគ្រប់គ្រងក្រុមអ្នកចូលមកទស្សនាទីក្រុង ហើយសង្ឃឹមថាអាជ្ញាធរមានផែនការច្បាស់លាស់ ពាក់ព័ន្ធនឹងការគ្រប់គ្រងក្រុមមនុស្សដ៏កុះករនេះ ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលគួរផ្តោតទំនួលខុសត្រូវរបស់ខ្លួន ទៅលើការការគ្រប់គ្រងក្រុមមហាជនក្នុងពិធីបុណ្យធំៗ ឲ្យមានតម្លាភាពជាងនេះ ហើយគួរផ្សព្វផ្សាយព័ត៌មានលម្អិត អំពីការរៀបចំគ្រប់គ្រងសុវត្ថិភាពនិងក្រុមមនុស្ស ដើម្បីជានា ថាសាធារណជនអាចដឹងពីនីតិវិធីទាំងនោះ ហើយដែលនឹងជានាបាននូវសន្តិសុខ សម្រាប់ព្រឹត្តិការណ៍បុណ្យទាំងមូល ។

[22] សារព័ត៌មានឌីខេមបូឌាដេលី ចំណងជើង "នគរបាលសុំក្រុមអាជីវកសម្រាប់ស្រាបៀរក្នុងថ្ងៃចូលឆ្នាំ" ចុះផ្សាយថ្ងៃទី១២ ខែមេសា ឆ្នាំ២០១១ ។

[23] សារព័ត៌មានឌីខេមបូឌាដេលី ចំណងជើង "បន្តផែនការរៀបចំសម្រាប់ពិធីបុណ្យអុំទូកនាខែក្រោយ" ចុះផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ។

[24] សារព័ត៌មានឌីខេមបូឌាដេលី ចំណងជើង "ស្ពានកោះពេជ្រថ្មីដើម្បីការពារនូវសោកនាដកម្មក្នុងពេលអនាគត" ចុះផ្សាយថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០១១។

មានអំណះអំណាង ថាគ្រោះថ្នាក់ដែលកើតពីភាពកកកុញនៃក្រុមមហាជន ភាគច្រើនអាចទប់ស្កាត់បាន តាមរយៈយុទ្ធសាស្ត្រសាមញ្ញសម្រាប់គ្រប់គ្រងក្រុមមនុស្ស ។[25] ឧបទ្ទវហេតុកកស្ទះជាប់គ្នាដ៏មហន្តរាយ អាចកើតឡើងនៅពេលដែលមនុស្សប្រមូលផ្តុំគ្នា ក្នុងទ្រង់ទ្រាយធំ ជាពិសេស នៅពេលដែលវិធានការប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងក្រុមមហាជន មានលក្ខណៈធូរលុង និងមិនគ្រប់គ្រាន់ ។ ប្រហែលជាមេរៀនដកពិសោធន៍ដ៏សំខាន់ គឺថាឧបទ្ទវហេតុកកស្ទះជាប់គ្នាជាច្រើន មិនមែនពុំអាចរំពឹងទុកបាន ឬមិនអាចជៀសវាងបាននោះទេ ។ បណ្តាឧបទ្ទវហេតុទាំងនោះកើតឡើង ក្នុងសណ្ឋាននិងលក្ខខណ្ឌ ដែលអាចរំពឹងទុកជាមុនបាន ។ ជាការសំខាន់ផងដែរ គឺថាក្រុមបុគ្គលិកផ្នែកព្យាបាល ផ្នែកសង្គ្រោះបន្ទាន់ និងផ្នែកពង្រឹងការអនុវត្តច្បាប់ គួរត្រូវបានហ្វឹកហ្វឺនឲ្យបានគ្រប់គ្រាន់ និងប្រុងខ្លួនជាស្រេច សម្រាប់ឧបទ្ទវហេតុបែបនោះ ទើបអាចមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ប្រសិនកើតមានបញ្ហាណាមួយ នៅក្នុងព្រឹត្តិការណ៍បុណ្យជាតិធំៗ នៅពេលអនាគត ។ ម.ស.ម.កផ្តល់អនុសាសន៍ ថារដ្ឋាភិបាលគួរស្វែងរកជំនួយពីជំនាញការ ដើម្បីអាចរៀបចំផែនការបានគ្រប់គ្រាន់ សម្រាប់ពិធីបុណ្យនាពេលអនាគត ។

នៅចុងបញ្ចប់ មនុស្សចំនួនជាង ៣៥០ នាក់ បានទទួលមរណភាពរួចទៅហើយ ក្នុងរាត្រីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលនេះជាតួលេខដ៏ច្រើននិងដ៏រន្ធត់ ជាងពេលណាៗទាំងអស់ ។ អាជ្ញាធរនិងសាធារណជនមួយភាគធំ ទំនងជាភ្លេចអំពីតួលេខនេះបាត់ទៅហើយ ។ ជនរងគ្រោះទាំងអស់និងគ្រួសារ គួរទទួលបាននូវអ្វីដែលប្រសើរជាងនេះ ។ យ៉ាងហោចណាស់ ពួកគាត់ត្រូវបានគេជំពាក់នូវការធានាមួយ ដែលថាវិធានការត្រូវបានរៀបចំជាស្រេចគ្រប់ជំហាន ដើម្បីធានាថាព្រឹត្តិការណ៍ ដែលអាចជៀសវាងបានបែបនេះនឹងមិនអាចកើតមានទៀតឡើយ ហើយថាមេរៀនពីគ្រោះឧបទ្ទវហេតុនេះ នឹងត្រូវបានដកពិសោធន៍រៀនសូត្រ ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងលោក អ៊ូ វីរៈ (ទូរស័ព្ទ ៖ +៨៥៥ (0) 1240 4051 ឬអ៊ីម៉ែល ៖ ouvirak@cchrcambodia.org) ។

[25] វិបសាយ ៖ www.crowddynamics.com (ហ្វ្រុន ចន) ខែមករា ឆ្នាំ២០០២ ចំណងជើង "មូលហេតុ និងការការពារគ្រោះថ្នាក់ដែលបណ្តាលមកពីក្រុមមនុស្សច្រើន" ។